Prek Leap National College of Agriculture

# សាលាជាតិកសិកម្ម ព្រែកលៀប

សាលាជាតិកសិកម្មព្រែកលៀប (**ភពល**) គឺជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលបានផ្តល់ការអប់រំលើជំនាញវិទ្យាសាស្ត្រកសិកម្មកម្រិតបរិញ្ញាបត្រនិងបរិញ្ញាបត្ររង។

**ភពល** មានចក្ខុវិស័យនឹងក្លាយជាគ្រឹះស្ថានអប់រំបណ្តុះបណ្តាល និងស្រាវជ្រាវផ្នែកកសិកម្មនាំមុខមួយនៅកម្ពុជា ដែលមានបេសកកម្មដូចតទៅ៖

1. បណ្តុះបណ្តាលប្រកបដោយការច្នៃប្រឌិត ត្រិះរិះពិចារណា បទពិសោធន៍ជាក់ស្តែង និងសម្របបានការប្រែប្រួលវិទ្យាសាស្ត្រ សង្គម និងធម្មជាតិ
2. ជំរុញការស្រាវជ្រាវ ដែលរួមចំណែកដល់ការកសាងចំណេះដឹងនិងគោលនយោបាយ
3. កសាងសហគ្រិនភាព និងអាកប្បកិរិយាឆ្លើយតបដោយប្រសិទ្ធភាពចំពោះការប្រែប្រួលក្នុងជីវិតនិងការងារ
4. រួមចំណែកអភិវឌ្ឍសហគមន៍តាមរយៈសកម្មភាពសង្គម និងវប្បធម៌



# វគ្គបណ្តុះបណ្តាល ថ្នាក់វិញ្ញាបនបត្រកម្រិត ទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម

**ពន្យាពេលថ្ងៃផុតកំណត់ទទួលពាក្យ រហូតដល់ថ្ងៃទី ១២ ខែកញ្ញា ឆ្នាំ២០១៨**









# សេចក្តីជូនដំណឹងស្តីពីការជ្រើសរើសយុវជនវ័យក្មេងឲ្យចូលរៀនវគ្គបណ្តុះបណ្តាលថ្នាក់វិញ្ញាបនបត្រកម្រិត **ទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម**

**វគ្គបណ្តុះបណ្តាលថ្នាក់វិញ្ញាបនបត្រកម្រិតទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម** មានកម្មវិធីបណ្តុះបណ្តាលរយៈពេល៣ខែ ដែលបានរៀបចំ និងអភិវឌ្ឍ ស្របតាមគោលនយោបាយផ្សព្វផ្សាយកសិកម្ម ដោយមានការជ្រោមជ្រែងពីអគ្គនាយកដ្ឋានកសិកម្ម និងអ្នកឯកទេស ក្រោមការគាំទ្រពីកម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់នឹងបម្រែបម្រួលអាកាសធាតុ (ASPIRE) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម** គឺជាធនធានមនុស្សដ៏សំខាន់មួយក្រុម នៃការងារផ្សព្វផ្សាយកសិកម្មក្នុងចំណោម ភ្នាក់ងារផ្សព្វផ្សាយភូមិ ភ្នាក់ងារផ្សព្វផ្សាយឃុំ និងអ្នកឯកទេសផ្សព្វផ្សាយដែលជាអ្នកមានចំណេះដឹងវិទ្យាសាស្ត្រកសិកម្ម និងទទួលបានការបំពាក់បំប៉នពីការងារផ្សព្វផ្សាយកសិកម្ម ។ ធនធានមនុស្សទាំងនេះបាននិងកំពុងកសាង ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សហគមន៍ និងការអភិវឌ្ឍជនបទ ។

**ភារកិច្ច** របស់ទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម គឺផ្តល់យោបល់ និងពាំនាំនូវបច្ចេកទេសកសិកម្ម ដែលសមស្រប ពង្រីកបច្ចេកទេស និងបច្ចេកវិទ្យាកសិកម្មដល់មូលដ្ឋានកសិករ ទាំងកសិករខ្នាតតូច និងកសិករក្រីក្រ ក្នុងការបង្កើនផលិតភាពធនធានដែលកសិករមាន និងការលក់ដូរដើម្បីប្រាក់ចំណេញ ។

**ឱកាសការងារ** របស់ទីប្រឹក្សាផ្សព្វផ្សាយកសិកម្ម គឺអាចធ្វើការជាមួយសហគមន៍ ក្រុមហ៊ុនកសិកម្ម និងមន្ទីរស្ថាប័នក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងបរិស្ថាន និងអង្គការក្រៅរដ្ឋាភិបាលជាដើម ។

**ចំណេះដឹង និងបំណិន** ដែលទទួលបានពីវគ្គបណ្តុះបណ្តាលនេះ គឺមានដូចជា គន្លឹះសំខាន់ៗសំរាប់ការផ្ទេរបច្ចេកវិទ្យាកសិកម្ម ដែលបានអនុវត្តជោគជ័យ ការវាយតម្លៃសក្តានុពលផលិតភាពកសិកម្ម ការធ្វើផែនការផលិតកម្ម និងការធ្វើពាណិជ្ជកម្មកសិផលរួមទាំងចំណេះដឹងនិងបំណិនវិភាគផ្សេងទៀតដែលជាមូលដ្ឋានសម្រាប់ផ្តល់យោបល់ពីខ្សែសង្វាក់ផលិតកម្ម និងពាណិជ្ជកម្មកសិផលរបស់កសិករ។

## លក្ខខណ្ឌជ្រើសរើស

បេក្ខជនដាក់ពាក្យសុំចូលរៀនវគ្គនេះត្រូវបំពេញលក្ខខណ្ឌចាំបាច់ដូចខាងក្រោម:

- មានសញ្ញាបត្របរិញ្ញាបត្រវិទ្យាសាស្ត្រកសិកម្ម ឬ
- មានសញ្ញាបត្របរិញ្ញាបត្រដែលជាជំនាញពាក់ព័ន្ធនឹងកសិកម្មនិងអភិវឌ្ឍន៍ជនបទ
- មានអាយុចាប់ពី ២៥ ទៅ ៣៥ ឆ្នាំ
- មានលិខិតអនុញ្ញាត្តិពីអង្គភាពសាមីុ បើជាមន្ត្រីរាជការ ឬបុគ្គលិកក្រុមហ៊ុនឯកជន

## ទីកន្លែងសុំពាក្យនិងដាក់ពាក្យចូលរៀន

- នៅការិយាល័យ ASPIRE សាលាជាតិកសិកម្មព្រែកលៀប ឬអាចទាញយកពីគេហទំព័រ www.pnsa.edu.kh
- ពាក្យសុំចូលរៀនអាចផ្ញើឲ្យលោក អែម សូរ៉ានី តាមអ៊ីម៉ែល emsorany@yahoo.com និងភ្ជាប់ឯកសារជា PDF ដូចខាងក្រោម៖
  1. សេចក្តីចំណាប់អារម្មណ៍ ១ច្បាប់
  2. ប្រវត្តិរូបសង្ខេប ១ច្បាប់ ដែលមានបិតរូបថត 4x6 ទើបថតថ្មី១សន្លឹកផង
  3. សញ្ញាបត្របរិញ្ញាបត្រ ឬវិញ្ញាបនបត្រ ថតចម្លង ១ច្បាប់
  4. លិខិតអនុញ្ញាត្តិពីអង្គភាពសាមីុ ថតចម្លង១ច្បាប់

ចំណាំ៖ បើដាក់ពាក្យតាមអ៊ីម៉ែល ហើយជាប់ជាបេក្ខជនក្នុងដំណាក់កាលសម្ភាសន៍ សូមយកមកជាមួយនូវច្បាប់ដើមនៃឯកសារខាងលើផង ។

## ចំនួនកំណត់ជ្រើសរើស៖ ៣០ នាក់

## កាលបច្ឆេទសំខាន់ៗ

- ផុតកំណត់ទទួលពាក្យ ១២ កញ្ញា ២០១៨
- ប្រកាសបេក្ខជនត្រូវតាមលក្ខណៈវិនិច្ឆ័យ និងសម្ភាសន៍ ១៣ - ១៤ កញ្ញា ២០១៨
- ចូលរៀន ១៧ កញ្ញា ២០១៨

## ទីកន្លែងសិក្សា

វគ្គនេះនឹងចូលរៀននៅសាលាជាតិកសិកម្មព្រែកលៀប រយៈពេល ៣ខែនេះ ។

## ការឧបត្ថម្ភថវិកា

ក្នុងអំឡុងពេលសិក្សា៣ខែនេះ បេក្ខជននឹងទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែចំនួន US$ ៣៦០ សំរាប់ អាហារនិងការស្នាក់នៅក្នុងសាលា។ ឯកសារសិក្សា និងទស្សនកិច្ចសិក្សាតាមខេត្តជាបន្ទុកចំណាយរបស់សាលា ។ ប៉ុន្តែ សាលាមិនមានផ្តល់ប្រាក់ DSA ពេលចុះទស្សនកិច្ចសិក្សាតាមខេត្តឡើយ ។

## ពេលវេលាសិក្សា

១ថ្ងៃ៨ម៉ោង និង ៥ថ្ងៃក្នុង១សប្តាហ៍ រយៈពេល ៣ខែ ពេញ ។

## ព័ត៌មានបន្ថែម

សូមទាក់ទងមកកាន់ការិយាល័យ ASPIRE នៃសាលាជាតិកសិកម្មព្រែកលៀប៖

HP: 012-409-169

HP: 016-269-562